# រឿង អាមាត្យរក្សាញ្ញ៉ៅព្រះរាជទ្រព្យ

មាននិទានមួយដំណាលថា : មានអាមាត្យម្នាក់តែងរក្សានិងរាប់ផ្លែញ្ញ៉ៅព្រះរាជទ្រព្យ របស់ព្រះមហាក្សត្រមួយអង្គ កាលណាផ្លែញ្ញ៉ៅនោះទុំ ក៏បេះយកទៅថ្វាយជានិច្ចពុំដែលខាន គាប់ជួនថ្ងៃមួយនោះ បុរសម្នាក់កាន់ទំពក់ទៅបេះផ្លែញ្ញ៉ៅ ដើរទៅក្បែរខាងដើមញ្ញ៉ៅ ដែលអាមាត្យនៅចាំរក្សានោះ ។ អាមាត្យមើលទៅ យល់បុរសនោះកាន់ផ្លែញ្ញ៉ៅនៅថ្នក់ ទំពក់នៅដៃ ក៏ទៅរាប់ផ្លែញ្ញ៉ៅនៅដើមនោះមើល ឃើញតែទងទទេទើបគិតថា " សមជាអាលីទំពក់នឹងផ្លែញ្ញ៉ៅដើរទៅអម្បាញ់មិញ នេះឯង ជាចោរលួច " ។ អាមាត្យក៏រត់ទៅតាមចៅនោះ ឃើញមានផ្លែញ្ញ៉ៅនៅថ្នក់ទំពក់នៅដៃមែន ហើយក៏ចាប់កោះយកទៅប្ដឹងចៅក្រមថា " ចៅនេះឯង ជាចោរលួចផ្លែញ្ញ៉ៅព្រះរាជទ្រព្យ ខ្ញុំចាប់បានផ្លែញ្ញ៉ៅនៅថ្នក់ទំពក់នៅដៃ " ។

ចៅក្រមដណ្ដឹងសួរថា " ចៅឯងជាចោរលួចបេះផ្លែញ្ញ៉ៅព្រះរាជទ្រព្យមែនឬទេ ? " ។ ចៅនោះឆ្លើយថា " ខ្ញុំមិនមែនជាចោរលួចទេ, ឯផ្លែញ្ញ៉ៅនេះខ្ញុំបេះមកពីព្រៃដទៃទៀតទេ " ។ ទើបចៅក្រមនាំសេចក្ដីនោះ ទៅក្រាបបង្គំទូលព្រះមហាក្សត្រតាមដំណើរសេចក្ដីនោះសព្វគ្រប់ ។

ព្រះមហាក្សត្រមានបន្ទូលថា "កុំអាលឲ្យគាបវាឡើយ" ហើយត្រាស់បង្គាប់ឲ្យយកផ្លែញ្ញ៉ៅអំពីចៅនោះ ទៅដាក់ផ្ទាប់ទល់នឹងទង ដែលផ្លែញ្ញ៉ៅជ្រុះចេញទៅនោះ តើត្រូវឬមិនត្រូវ រួចសឹមទម្លាក់ផ្លែញ្ញ៉ៅនោះទៅដី ហើយពិចារណារកដើមហេតុឲ្យឃើញពិតប្រាកដសិនបើឃើញថា គួរមានទោសសឹមធ្វើទោសវា " ។

អាមាត្យទទួលព្រះរាជឱង្ការ ហើយយកផ្លែញ្ញ៉ៅនោះទៅដាក់លនឹងទងញ្ញ៉ៅ ឃើញថាមិនត្រូវទំនងគ្នាសោះ ហើយទម្លាក់ទៅដី ផ្លែញ្ញ៉ៅនោះក៏ជ្រុះទៅក្នុងថ្លុកកប់ភក់ទៅ ។ ព្រះអង្គឲ្យយកផ្លែញ្ញ៉ៅ ដែលជ្រុះអំពីមុននោះទៅដាក់ផ្ទាប់លមើល ក៏ឃើញត្រូវនឹងទងនោះមែន ហើយត្រាស់បង្គាប់ឲ្យយកផ្លែញ្ញ៉ៅខុសនឹងទងវាឲ្យទៅបុរសលីទំពក់វិញ ហើយឲ្យបើកលែងទៅ ។ ចៅនោះក៏យកទំពក់និងផ្លែញ្ញ៉ៅរបស់ខ្លួនទៅកាន់ទីលំនៅអាត្មាវិញ ។

ព្រះមហាក្សត្រទ្រង់រកសេចក្ដីពិត បានឃើញជាក់ស្ដែងដូច្នេះហៅសុគតិគមនំ ត្រូវតាមគន្លងធម៌ហោង ។